ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ
# ជូនបងប្អូនកម្មករនិយោជិតនៃរោងចក្រស្បែកជើង អ.ជី ហ្វ៊ុតវែរ (ខេមបូឌា) ឯ.ក
**( R.G FOOTWEAR (CAMBODIA) CO., LTD. )**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតនៃ**រោងចក្រ អ.ជី ហ្វ៊ុតវែរ (ខេមបូឌា) ឯ.ក** ដែលមានទីតាំងស្ថិតនៅផ្លូវលំ ភូមិអណ្តូង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ជ្រាបថា ដោយសារឧបទ្ទវហេតុអគ្គិភ័យឆេះរោងចក្រទាំងស្រុង កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ កន្លងទៅ ធ្វើឱ្យរោងចក្រមិនអាចស្តារលទ្ធភាពដំណើរការអាជីវកម្មឡើងវិញក្នុងពេលឆាប់ៗបានឡើយ។ ក្នុងកាលៈទេសៈមិនប្រាកដអំពីពេលវេលា និងលទ្ធភាពនៃការស្វែងរកទុនបន្ថែមថ្មីដើម្បីជួសជុល សាងសង់ និងបំពាក់សម្ភារ បរិក្ខារឡើងវិញ រោងចក្របានប្រកាសបិទដំណើរការរបស់ខ្លួនទាំងស្រុង ដែលនាំឱ្យកិច្ចសន្យាការងាររបស់បងប្អូនកម្មករនិយោជិតទាំងអស់ ត្រូវបានរំលាយផងដែរ។

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកោះអញ្ជើញតំណាងរោងចក្រមកជួបពិភាក្សាអំពីការទូទាត់អត្ថប្រយោជន៍តាមច្បាប់ជូនបងប្អូនកម្មករនិយោជិត។ ជាលទ្ធផល បើទោះបីរោងចក្រកំពុងខ្វះខាតថវិកាទូទាត់ទៅភាគីជាច្រើនក៏ដោយ ក៏ម្ចាស់រោងចក្រនឹងផ្តល់អាទិភាពខិតខំស្វែងរកថវិកាពីប្រភពនានាមកបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ ជូនបងប្អូនកម្មករនិយោជិត ស្របទៅតាមច្បាប់ស្តីពីការងារឱ្យបានមុនគេ។ ដោយហេតុថា រោងចក្រទើបដំណើរការបានក្នុងរយៈពេលខ្លី ហើយបងប្អូនកម្មករនិយោជិតប្រើប្រាស់កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC) ដូច្នេះ បងប្អូនកម្មករនិយោជិតនឹងទទួលបានចំនួន ៣ចំណុច ដូចខាងក្រោម៖

១. ប្រាក់ឈ្នួលដែលមិនទាន់បានបើកក្នុងខែចុងក្រោយ (មាត្រា១១៦)
២. ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)
៣. ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥% (មាត្រា៧៣)

សូមបងប្អូនកម្មករនិយោជិតអញ្ជើញទៅ **សាលាស្រុកអង្គស្នួល** ដែលស្ថិតនៅផ្លូវជាតិលេខ៤ ភូមិព្រៃពពេល ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ដើម្បីបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗនៅ **ថ្ងៃសៅរ៍ ទី៣០ ខែមីនា ឆ្នាំ២០២៤** ចាប់ពីម៉ោង **៨:៣០ នាទីព្រឹក** តទៅ ទៅតាមបញ្ជីឈ្មោះ និងលេខរៀង ដែលក្រសួងនឹងបិទផ្សាយនៅសាលាស្រុកអង្គស្នួល នៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤ មុនបើកប្រាក់។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ ទូរសារៈ[illegible] ២៧ ៦៩

សូមបងប្អូនកម្មករនិយោជិត យកមកជាមួយនូវឯកសារដូចខាងក្រោម៖

១. ប័ណ្ណ (កាត) សម្គាល់ខ្លួនកម្មករនិយោជិត (ច្បាប់ដើម) ឬកិច្ចសន្យាការងារ និងសៀវភៅការងារកម្មករនិយោជិត ឬប័ណ្ណសមាជិក ប.ស.ស. ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

២. ប័ណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក៖

- លោក ធុល នាង ០៨៨ ២២២ ៩៦៦៦
- លោក វ៉ា សុវណ្ណពិសាល ០១២ ៤៩៩ ៩៩២

ទន្ទឹមនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមអំពាវនាវដល់បងប្អូនកម្មករនិយោជិតដែលមិនទាន់មានការងារថ្មីធ្វើ សូមមកទទួលឱកាសការងារថ្មីពីមជ្ឈមណ្ឌលការងារចល័តនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដែលនឹងដាក់ប្រចាំការនៅខាងមុខរោងចក្រចាប់ពី ថ្ងៃចន្ទ ទី២៥ ខែមីនា ឆ្នាំ២០២៤ តទៅ និងនៅមុខសាលាស្រុកអង្គស្នួល នៅថ្ងៃសៅរ៍ ទី៣០ ខែមីនា ឆ្នាំ២០២៤ ឬមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារដែលស្ថិតនៅក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬធ្វើការទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០៧៧ ២៣២ ៣៧៨/០១៦ ៧៨៦ ៦៥៥។

ក្រសួងសូមថ្លែងអំណរគុណដល់ម្ចាស់រោងចក្រ ដែលមានការទទួលខុសត្រូវខ្ពស់ និងខិតខំរកថវិកាមកបើកជូនកម្មករនិយោជិតតាមច្បាប់ស្តីពីការងារ និងតាមសំណូមពររបស់ក្រសួង ជាពិសេស សូមអរគុណដល់បងប្អូនកម្មករនិយោជិតដែលបានរក្សាភាពស្ងប់ស្ងាត់ ប្រកបដោយមនោសញ្ចេតនាចូលរួមសោកស្តាយចំពោះឧបទ្ទវហេតុនេះ និងទុកឱកាសឱ្យក្រសួង និងរោងចក្ររួមគ្នាដោះស្រាយបញ្ហានេះដោយសន្តិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិតទាំងអស់ជ្រាបជាព័ត៌មាន និងអញ្ជើញទៅបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗរបស់ខ្លួនតាមពេលវេលា និងទីតាំងកំណត់កុំបីខាន។

ថ្ងៃអាទិត្យ ១៥កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤